ប្រលោមលោកផ្នែកមនោសញ្ចេតនា



# ទ្វីបក្តីក្នុងកបរក្ខុខិស្នេហា

ដោយ

អ្នកស្រីដួង - រដ្ឋា

ជាអ្នកនិពន្ធដែលបានទទួលរង្វាន់នូ-ហាចលេខ ១ ខាងប្រលោមលោក
ខ្នាតវែង "ទារុណកម្មនៃចិត្តភក្តិ "ក្នុងសម័យមហោស្រពខ្មែរឆ្នាំ១៩៨៧
នាក្រុងឡុងបិច រដ្ឋការលិហ្វ័រញ៉ា

-"ចាំសបង ! បងលើកអូនអោយអង្គុយសិនទៅ !"

គ្មានថ្នាំអ្វីដែលពិសេសជាងថ្នាំបានជួបសង្សារបណ្ដូលចិត្តដែលនាងនឹកថាគេស្លាប់បានទៅហើយនោះទេ ។នាងស្រីប្រឹងងើបឡើងតាមកំឡាំងដៃសារុធលើក ញញឹមបបរអស់មួយចាន រួចនាងចាប់ផ្ដើមសួរប្រុសស្នេហ៍នាង .....

-"បង ! រឿងនោះយ៉ាងណាទៅវិញបង ?"

-"អូនគេងទំរេតខ្លួនសិនទៅ ចាំបងនិយាយប្រាប់ណា៎ !"

សារុធដាក់ស្រស់ស្រីទំរេតលើខ្នើយ ចេញមើលទៅខាងក្រៅបន្តិចក៏មកដាក់ខ្លួនអង្គុយទន្ទឹមនឹងនាងហើយនិយាយថា ៖

-"នៅយប់ដែលបងនឹងសុគន់បំរុងរត់ចេញមកវិញនោះបងបានបីម្ដាយបងចេញពីគ្រង់សេដើម្បីមករកជួបនិងសុគន់ នឹពុកមាសុគន់មិនដឹងជាមកចាំបងពីអង្កាល់ហើយក៏ហៅបងទៅកសាងពីរឿងដែលបងចង់រត់នេះ ។ដូចនេះពេលគ្រាប់ផ្លោងចូលចំគ្រង់សេបងនោះបងនិងម៉ែបានរត់ចេញផុតទៅហើយ ។ក្រោយមកដោយខ្លាចបងនិងម៉ែរត់ទៀតគេបានជន្លៀសបងទៅកន្លែងដាច់ស្រយាលមួយ អោយបងធ្វើការវាយថ្មយ៉ាងវេទនាឯម៉ែគេអោយគាត់ដេរស្បូវទាំងឈឺ (និយាយដល់កន្លែងនេះសារុធឈប់បន្តិច ខំសំរួលសំឡេងសារជាថ្មី) ជីវិត

ព្រឹកព្រលឹមឡើងរដ្ឋាដឹងខ្លួនស្រែកហៅរកម្ដាយ ឪពុកនាង ៖

-"ម៉ែ ! ពុក ! "

នាងរកមើលជុំវិញខ្លួននាងគិតថានាងប្រាកដជាមិនច្រឡំទេ ព្រោះផ្ទះនេះពិតជាផ្ទះរបស់នាង គ្រាន់តែនាងប្ដូរកន្លែងមកខាងក្រៅតែប៉ុណ្ណោះ ។ឮសំឡេងនេះភ្លាម យោធាចំខ្សែកក៏ខិតមកអង្គុយរួចដាក់មុខចំភក្ត្រស្រស់ស្រី ។

-"ពុទ្ធោ ! បងវុធ ! បងមកវិញហើយមែនទេ ?
ខ្ញុំយល់សប្តិឬមួយយ៉ាងណា ? "

ដើម្បីកុំអោយនាងស្រីមានការរំភើបក្នុងចិត្តខ្លាំងពេក យោធាចំខ្សែកនិយាយឡើងថា ៖

-"បង ! គឺ បងវុធមែនណ៎ា ! អូនមិនមែនយល់សប្តិទេ !"

-"ចុះហេតុអីបានជាបងនៅមានជីវិតទៅវិញ ? "

-"រឿងនេះវែងឆ្ងាយណាស់អូន ! អូនដេីបញ៉ាំបបរសិនទៅចាំបង និយាយប្រាប់ ! "

បងនិងម្ដាយរស់យ៉ាងប្រភិតប្រផើយ គេអោយបាយពេលព្រឹកអត់ពេលល្ងាច ។ម៉ែឈឺចុកចាប់ពេញខ្លួនស្រែកយំស្ទើរផុតដង្ហើម នៅជុំវិញខ្លួនឃើញតែគុម្ពព្រៃចនិងដើមខ្លុង រកមនុស្សម្នាក់គ្មានសោះ ។មួយខែក្រោយមកអង្គការមកនិយាយដាក់លក្ខខណ្ឌនឹងបងថា ៖

-"បើមិត្តឯងសុខចិត្តទៅធ្វើជាយោធា យើងនឹងអោយថ្នាំព្យាបាល ដល់ម្ដាយមិត្តឯង តែបើពេលទៅធ្វើយោធាឯងចង់រត់ចូលខាង ខ្មាំងទៀតនោះ ជីវិតម្ដាយឯងនៅក្នុងកណ្ដាប់ដៃយើង មិត្តឯងគួរតែយល់ហើយ មែនទេ ? ដោយមិនចង់ឃើញម្ដាយមានការឈឺចាប់តទៅទៀតនោះបង ក៏សុខចិត្តទៅចោលម្ដាយ ដើរធ្វើយោធាដើម្បីប្ដូរយកថ្នាំមកព្យាបាលគាត់ ។ដំបូងមួយខែ អង្គការអោយមកមើលម្ដាយម្ដង ។ក្រោយមកបីខែ ទៅ ប្រាំខែ ។ តែឥឡូវរហូតដល់ជាង បីឆ្នាំនេះបងនៅមិនទាន់បានឃើញមុខគាត់នៅឡើយទេ "

-"បង ! ស្អីទៅជាអង្គការ ? "

-"អង្គការជារដ្ឋអំណាចជាន់ខ្ពស់របស់ខ្មែរក្រហម គ្មាននរណាមួយហ៊ានប្រកែកនឹងអង្គការបានទេ ។ក្រោយមកគេបញ្ជូនបងអោយទៅវាយនៅខេត្តកំពង់ឆ្នាំង ។បង

ត្រូវទាហានចាប់ខ្លួនបាន ។ហេតុតែជីវិតបងមិនអស់ បងបានស្គាល់បញ្ញាការការម្នាក់ដែលធ្លាប់រៀនទៅវិទ្យាល័យ យើង ហើយធ្លាប់រស់នៅក្នុងភូមិជាប់យើងទៀត "

-"ជានរណាទៅបង ? "

រដ្ឋាសួរសារុធដោយក្តីអន្ទះសារចង់ដឹង ។

-"អូនប្រាកដជាស្គាល់គាត់ហើយ គាត់ធ្លាប់រស់នៅវត្តកែវសុវណ្ណនោះអី គឺបងប៊ុន-សួរ ដែលបងនិងគាត់ធ្លាប់លេះផ្លែក្រូចថ្លុងមកធ្វើជាបាល់ទាត់ នៅពេលល្ងាចៗលើវាលខ្សាច់នៅមុខវត្តនោះ អី ! "

-"អ៊ុំ ! អូននឹកឃើញហើយ កាលនោះគាត់ប្រឡងសញ្ញាបត្រមធ្យមសិក្សាភាគទី១ធ្លាក់ នៅឆ្នាំ ១៩៧២ ក៏ចូលធ្វើទាហានបាត់ទៅ "

សារុធបន្តរឿងទៀត...

"គាត់បានដោះលែងបងអោយរួចខ្លួន ព្រមទាំងហៅបងអោយជួយធ្វើការគាត់ផង ។តែបងបាននិយាយប្រាប់ពីដំណើររឿងរ៉ាវរបស់បងអោយគាត់ស្តាប់ គាត់ក៏យល់ព្រមជឿតាមបង ។នៅឆ្នាំ១៩៧៥ ក្នុងខែមិនា មានការវាយចំផ្ចាច់ព្រាត់ម្តងទៀតក្នុងខេត្តកំពង់ឆ្នាំង ។អង្គការចង់ចាប់កំហុសបងដោយដឹងថា បងមានការទាក់ទងជា

មួយទាហានបានជាត្រឡប់មកវិញដោយស្រួលៗម៉្លេះ ។ គេបានអោយបងចាំ ឃ្លាំងសម្ភារះសឹកដែលជាមុខនាទីសំខាន់ក្នុងកងទព័វិញម្តង ។ដោយបងអាចការពាររក្សាឃ្លាំងយ៉ាងអស់អាចបានគេក៏អោយបងកាន់ឃ្លាំងប្រចាំតំបន់រហូតមកដល់សព្វថ្ងៃនេះ "

-"បងតាំងពីបងចូលធ្វើយោធាមក បងមានបានសំឡាប់មនុស្សអស់ប៉ុន្មានដែរ ? "

វដ្ឋាសួរចង់ដឹង ។

-" បានដែបងនៅសស្អាតមិនទាន់ដែលប្រឡាក់ឈាមខ្មែរម្នាក់នៅឡើយទេអូន ! ។បងទៅធ្វើយោធាមិនមែនព្រោះរឿងនយោបាយ ចង់ឈ្នះចាញ់ ធ្វើជាព្រះឬធ្វើជាមារនោះទេ បងទៅព្រោះចង់បានថ្នាំមកព្យាបាលម្តាយតែប៉ុណ្ណោះ ចុះអូនវិញ ហេតុអ្វីបានជា អូនជាជំងឺដល់ថ្នាក់នេះ ? ហ្នឹងព្រោកដជាបាត់បងយូរហើយមែនទេ ? "

-"ចាំសបង ! នាងស្រីនិយាយទាំងខ្មាសអៀន បងវល់តែស្តាប់បងនិយាយ អូនភ្លេច ! តើពុកនឹងម៉ែគាត់អញ្ជើញទៅណាហើយ ? ដូចជាមិនឃើញគាត់មកក្បែរអូនដូចកាលមុនសោះ ?"

សារុធជកដង្ហើមធំបញ្ចេញខ្យល់ដើម្បីបន្ធូរការតានតឹងក្នុងខ្លួន ភ្នែកគេសំឡឹងមើលតាមបង្អួចបង្អើរអារម្មណ៍ទៅឆ្ងាយ ក៏និយាយប្រាប់នាងថា ៖

-"ពេលបងមកដល់បងឃើញតែរូបអូនគេងស្ដូកស្ដឹងលើផ្ទះតែ ម្នាក់ឯង ឯអ្នកភូមិម្នាក់ក៏រកមិនមានដែរ "

-" ម៉េចក៏អញ្ចឹងទៅវិញ ? (នាងឧទានដោយភ្ញាក់ផ្អើល ) ប្រហែល ជាដូចបងរុធថាមែនហើយ ព្រោះដូចជាគ្មានឮសំឡេងម៉ូតូឡានអីដូចពីមុនសោះ តើពុក ! ម៉ែ ដាច់ចិត្តទៅណាចោលខ្ញុំ ឬមួយក៏ពុកម៉ែស្មានថាខ្ញុំស្លាប់ទៅហើយបានជាទុកខ្ញុំនៅចោលយ៉ាងនេះ ? ហ៊ឹក ! ហ៊ឹក ! ហ៊ឹក ! "

-"យប់យំទៅអូន ! ពុក ម៉ែទៅចោលអូនមែន តែបងរុធរបស់អូន ឈប់ទៅណាចោលអូនទៀតហើយ !អូន ! អូនគេងសំរាកសិនទៅ ចាំអូនជាស្រួលបួលយើងនឹងដើររកគាត់ទាំងអស់គ្នា "

សារុធលួងលោមសង្សាររួចក៏ផ្ដេកនាងអោយគេងលើគ្រែវិញ ។

ពេលយប់បានកន្លងផុតទៅ ពេលថ្ងៃផ្លាស់វេនចូលមកជំនួស ។ មួយអាទិត្យបានកន្លងទៅយ៉ាងរហាស័ អាការរោគរបស់រដ្ឋាបានធូរស្បើយជាលំដាប់ ក្រោមការព្យាបាលរបស់ប្រុសស្នេហ៍នាង ។

តែរាល់ថ្ងៃនាងស្រីតែងសង្កេតឃើញសាវុធមានអាកប្បកិរិយា ខុសប្លែកពីមុនឆ្ងាយណាស់ទាំងឫកពារនិងសំដីសំដៅ ។ដើម្បី អោយអស់ចម្ងល់នាងស្រីដាច់ចិត្តសួរកំឡោះយោធាថា ៖

-"បង ! បងអាចប្រាប់អូនផងបានទេ ? "

-"រឿងអីទៅអូន ? "

-"អូនឃើញបងប្លែកពីមុនឆ្ងាយណាស់ ប្លែក ត្រង់ ....."

ដោយមិនបាច់អោយនាងស្រីបញ្ចប់ទាន់ នាយក៏ឆ្លើយឡើង ដោយយកដៃជ្រងសក់ទៅលើផង ។

-"បងប្លែកច្រើនមែន បងក៏ដឹងខ្លួនដែរ ។អូនធ្លាប់ ដឹងនិងស្គាល់រូបបងស្រាប់ហើយ បងធ្វើអ្វីមិនចូល ចិត្តអោយគេបង្ខំទេ ។អូនធ្លាប់ដឹងហើយថាបងស្អប់ របបអ្វីជាងគេ អូនអាចទាយត្រូវហើយ ។ អូនធ្លាប់ ដឹងថាតើពីដើមមកបងចូលចិត្តសំលៀកបំពាក់ខ្មៅទេ ? ។ រហូតមកដល់ពេលនេះខ្លួនបងហារស្លាក់ខ្នាក់ស្លែង តែ រកនិយាយប្រាប់មេឃប្រាប់ផ្កាយមិនកើត ។សព្វថ្ងៃ បងពិបាកចិត្តគិតមិនលេច គ្មានអ្វីដែលបន្សល់ចំពោះ រូបបងក្រៅពីរូបអូនម្នាក់ដែលជាសេចក្តីប្រាថ្នាជាចុង ក្រោយរបស់បងទេក្នុងជាតិនេះ ។រូបអូនជាជំនឿមរបស់ បង (និយាយដល់ត្រង់នេះយោធាសាវុធអួលដើមក ទឹក

ក្នុករលីងរលោងមួយរំពេច ) បងមកជួបអូនលើកនេះ និងមិនអោយអូនបែកពីទ្រូងបងជាលើកទីពីរជាច់ខាត ។ បង ! លែងទៅធ្វើជយោធាអ្វីទៀតហើយបងមានទោសធ្ងន់ណាស់ចំពោះអូន សូមអូនអភ័យទោសអោយបងផងណា ! "

(កំឡោះយោធាយកដៃច្របាច់ដៃសង្សារយ៉ាងណែនដោយក្ដីអាណិតនិងស្រឡាញ់ពន់ពេក )

-"រឿងយើងទាំងពីរគ្មានអ្វីដែលមកបំបែកបំបាក់យើងបានទៀតទេ ពេលយើងរកម៉ែនិងពុកឃើញ យើងរស់ជាប្ដីប្រពន្ធនិងគ្នាអស់មួយជីវិត មែនទេបង ?"

រដ្ឋានិយាយដោយសំដែងទឹកមុខញញឹម ។

សារុធងក់ក្បាលតបវិញជាចំឡើយ ។ទឹកមុខរដ្ឋាដែលធ្លាប់តែបាត់បង់សម្រស់ ឥឡូវប្រែជាស្រស់ញញឹមបីដូចជាបុប្ផាត្រូវទឹកសន្សើមយ៉ាងនោះដែរ ។តែផ្ទុយទៅវិញសារុធញញឹមទាំងស្រងូតស្រងាត់ដូចជាមានលាក់អាថ៌កំបាំងអ្វីមួយក្នុងដួងចិត្តរបស់គេដដែល ។

នៅថ្ងៃទី១ ខែមិថុនា ឆ្នាំ ១៩៧៥ អង្គការបានអនុញ្ញាតិអោយប្រជាជនដែលមានផ្ទះនៅទីក្រុងចូលមកយកអីវ៉ាន់ខ្លួនសំរាប់បរិភោគ ចំនួន ៥ម៉ោងគឺពីម៉ោង៩ព្រឹករហូតដល់

ម៉ោង២រសៀល ។អារម្មណ៍របស់តាសំនៅជឹតជាប់នឹងរឿង ខ្មោចប្រពន្ធដែលត្រូវគ្រាប់ស្លាប់និងកូនស្រីគាត់ដែលមិនទាន់ ជាច់ខ្យល់ស្រួលបួលផងជានិច្ច ។កាលបើពួកអង្គការបើក អោយទៅយករបស់របរជុំច្នោះ តាសំក៏រៀបចំរទេះគោតាំងពី ព្រលឹមស្រាងៗ ។គោលបំណងរបស់គាត់គឺទៅជីកខ្មោច អ្នកទាំងពីរយកមកធ្វើបុណ្យបញ្ចុះតាមប្រពៃណីខ្មែរ ។

អ្នកស្រុកខ្លះមិនទាន់ភ្ញាក់ស្រួលបួលផង តាសំចាប់ បំបោលគោយ៉ាងលឿនមិនទាំងអោយប្អូនគាត់ដឹងបន្តិចឡើយ ដើម្បីទៅដល់ទាន់ព្រលឹមត្រជាក់ ។ប្អូនប្រុសគាត់ឃើញដូច្នោះ ក៏កញ្ឆក់តែគ្រមារបង់កមួយ លោតឡើងរទេះតាសំហ៊ុយដី សំពោង ។

តាសំបររទេះមកដល់ផ្ទះកំសត់គាត់ស្របពេលដែលអង្គការ កំពុងបើកទ្វារអោយចូលទីក្រុង ។ក្នុងចិត្តតាសំគាត់កំពុង តែនឹកថាខ្មោចប្រពន្ធកូនគាត់មិនដឹងជាស្អុយពេញផ្ទះយ៉ាងណា ទេ ? គាត់យកថង់ផ្លាស្ទិច ៤- ៥ ផ្ទាំងមកទុករំស្រេច ។ប្អូន ប្រុសគាត់ ដើរតាមពីក្រោយគាត់ទាំងល្ហេល ៗ ហើយ និយាយពីក្រោយខ្នងតាសំថា ៖

-"ល្បងអើយ ! កុំចូលទៅអីធ្វើតែបុណ្យបញ្ជូនទៅ បានហើយ "

តាសំដើរដល់កាំជណ្តើរ ភ្នែកសំឡឹងទៅម៉ុងហុងជាមួយពណ៌

ក្រហមដែលចតចោលនៅក្រោមផ្ទះ ..... កំហឹងគាត់ឆេះឆោប ឈូលមួយរំពេច មុខគាត់ក្រហមដូចរងឹកភ្លើង តែមិនចេញ ស្តីមួយមាត់ ។ទៅដល់មាត់ទ្វាគាសំប្រឹងស្រង់ក្លិនខ្មោចប្រពន្ធកូន គាត់ ...... តែដូចជាមិនធុំក្លិនអ្វីសោះ ។ឯប្អូនប្រុសគាត់ដើរតោង ក្រមារគាសំពីក្រោយ ។នៅវេលាម៉ោង ៩ ព្រឹកក្នុងផ្ទះមិនទាន់ មើលឃើញអ្វីច្បាស់ណាស់ណាទេ ព្រោះបង្អួចខ្ទះនៅបិតជិតនៅឡើង ។ ចូលមកក្នុងផ្ទះបន្តិច គាសំឃើញអង្រឹងពណ៌ខ្មៅមួយចងនៅកណ្តាល ផ្ទះ.....ប្អូនគាសំទាញក្រមារបងគាត់ថយក្រោយ ៖

-"ល្បង ! ខ្មោចលងទេដឹង ? ចុះមានអង្រឹងអី ផងបង ? ប្រហែលជាខ្មោចបងស្រីដឹងលែង ខ្លួនទេដឹង ? "

-"កុំឆ្កួត ! គ្មានខ្មោចឯណាទេ ! "

គាសំនិយាយកម្ចាប្អូនគាត់ ហើយគាសំអូសប្អូនប្រុសអោយចូល ប្អូនប្រុសគាត់អូសគាសំចេញមកវិញ ទាញទៅទាញមក រហូតដល់គាសំរបូតក្រមារពីចង្កេះជ្រួលអុកគូថលើក្តារសូរទិស ធ្មេំអោយសារុំងដែលគេងលើអង្រឹងនិងវដ្ឋាគេងលើក្តារភ្ញាក់ ឡើង ......

-"នរណាហ្នឹង ? "

សារុំងស្រែកឡើងទាំងមមីងមម៉ើង ។

ឯប្អូនប្រុសគាសំស្មានតែខ្មោចលង ក៏លោតជើងពីរ-បី .....

-"ល្បែងរត់ ! ខ្មោចលងហើយ ខ្ញុំមិននៅទៀតទេ ខ្ញុំទៅមុនហើយ ! "

ថារួចគាត់ក៏ហាក់ផ្លោះកាំជណ្តើរទាំង៧កាំមកដល់ដីដោយមិនដឹងខ្លួន ។

-"ពុក ! ពុក ! (រដ្ឋាវិស្រែកឡើង ) កូនមិនទាន់ស្លាប់ទេពុក ម៉ែនៅឯណាពុក ? "

-"កូនអាយុវែងណាស់ នៅមានជីវិតរស់វិញ " តាសំនិយាយតបវិញ ។

ភ្លាមនោះសារុធដើរឡើងពីក្នុងអង្រឹងមកសំពះតាសំ

-"ពុក ! កូនមកវិញហើយ "

តាសំមិនចេញស្តីមួយមាត់ដាក់សារុធសោះ ។ឃើញដូច្នោះរដ្ឋាក៏ទៅជិតឪពុកនិយាយអង្វរថា ៖

-"ពុក ! គឺបងរុធជាអ្នកជួយកូនណាំពុក ! "

កំហឹងតាសំកាន់តែកើនល្បឿនឡើងជាលំដាប់ ជាហេតុធ្វើអោយកូនស្រីគាត់មានការងឿងឆ្ងល់និងកាយវិការនេះជាខ្លាំង ។តាសំស្រែកជះកំហឹងដាក់សារុធ ៖

-"ហ៊ឺស ! អាក្រពើ បាតដៃឯងប្រឡាក់សុទ្ធតែឈាមម្តាយឯង ឯងមានភ្នែកមើលទេ ? ថ្វីត្បិតតែឯងមិនបានសំឡាប់ដោយផ្ទាល់ដៃ តែក៏ជាបក្សពួករបស់អាតិរិច្ឆានឯងដែរ ។ម្តាយស្រឡាញ់វាស្មើរ

លេប ខំបីបាច់អោយវារៀនសូត្រអោយវាចេះដឹងខុសត្រូវ តែផ្ទុយទៅវិញឯងមកតបសងសង្គុណរបៀបហ្នឹងឬ ? ហ៊ឺស ! មកកូនស្រីទៅតាមពុក ! ពុកមិនអោយឯងនៅជួបមុខអាឃាដកនេះទៀតទេ ! "

រដ្ឋាដែលមិនដឹងសាច់រឿងអ្វីពិតប្រាកដ នៅឈរភាំងដូចរូបចំឆ្លាក់ ដោយនាងគ្មានកំលាំងកំហែងនឹងទប់កំបណ្តោយអោយតាសំអូសចុះទៅដីទាំងទីណាត់ទីណែង ។សាវុធគ្មានពាក្យអ្វីនិយាយតបនិងតាសំបន្តិចឡើយ ព្រោះរឿងនាយត្រូវតាសំយកមកហែកកកាយ ព្រមទាំងបំភ្លើសហួសពិការពិតទៀតផង ។

-"ពុក ! ស្តាប់កូនសិន ! (រដ្ឋាស្រែកអង្វរឪពុកនាង) ពុកយល់ ខុសហើយ បងវុធបានជួយជីវិតកូនដែរពុក !"

-"ពុក! ពុកអនុញ្ញាតិអោយកូនបានប្រាប់រឿងរ៉ាវពុកសិន !"

(សាវុធលត់ជង្គង់សំពះអង្វរតាសំ )

តាសំនៅមិនស្តាប់ គិតតែប្រឹងអូសកូនស្រីតាមកាំជណ្តើរចុះទៅដីទោះសាវុធតាមអង្វរតាសំយ៉ាងណាក៏គ្មានន័យអ្វីដែរ ។តាសំបញ្ជាអោយប្អូនគាត់ចាប់នាងរដ្ឋាដាក់រទេះ រួចគាត់អ្នកបំបោលគោចេញទៅ ។ពោធោសាវុធឈរស្រឡាំងកាំង តែម្នាក់ឯងនៅមុខផ្ទះឮតែសំឡេង រដ្ឋាស្រែកហៅឈ្មោះនាយល្វើយៗ រហូតដល់បាត់

តាមសំឡេងរទេះងឹតង់តៗ ដែលលាយនឹងត្រដោកគោទៅ ។